អគ្គនាយកដ្ឋាន
សុខភាពសត្វ និងផលិតកម្មសត្វ
ចូល
លេខ: ១២៣៧៤
ថ្ងៃទី: ២៥.០៥.២០២០
ម៉ោង:........................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានកិច្ចការរដ្ឋបាល
ចូល
លេខ........១២៦០
ថ្ងៃទី ២៩. ០៤. ២០. ២០
បញ្ជូន.......................

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : ៤១៧ សជណ.កជ

ថ្ងៃ ៣ ៦ កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មេសា ឆ្នាំ២០២០

## ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
## ជម្រាបជូន
## ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**កម្មវត្ថុ៖** ករណីសំណើសុំដាក់បញ្ចូលមាត់ច្រកអូរបីជាន់ ជាទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនស្ថិតនៅភូមិប្រាសាទ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ទៅក្នុងអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០១។

**យោង ៖** - លិខិតលេខ១៥០៨ កសក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ចំណារដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា ចំពោះករណីសំណើសុំដាក់បញ្ចូលមាត់ច្រកអូរបីជាន់ ជាទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនស្ថិតនៅភូមិប្រាសាទ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ទៅក្នុងអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០១ ទីស្តីការគណៈរដ្ឋមន្ត្រីឯកភាពតាមស្មារតីប្រជុំអន្តរក្រសួងចង្អៀត ដូចខាងក្រោម៖

១- បន្តជំរុញការបើកច្រកទ្វារតំបន់ព្រំដែន ៤៣ ដែលទទួលបានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាលរួចហើយ ជំនួសឱ្យការស្នើសុំបើកច្រកអូរបីជាន់ និងប្រគល់ភារកិច្ចជូនក្រសួងមហាផ្ទៃនិងរដ្ឋបាលខេត្តបន្ទាយមានជ័យ អនុវត្តការងារនេះដោយសហការជាមួយភាគីថៃតាមរយៈកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃដែលនឹងប្រព្រឹត្តទៅនាពេលខាងមុខ។

២- គោរពអនុវត្តតាមចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ សូមក្រសួងមហាផ្ទៃបន្តអនុវត្តការងារវិសោធនកម្មអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០១ ឱ្យស្របទៅនឹងស្ថានភាពវិវឌ្ឍជាក់ស្តែងនាពេលបច្ចុប្បន្ន ដែលមានការប្រែប្រួលទាំងស្ថានភាពច្រកទ្វារ ចំនួនច្រកទ្វារ និងសមត្ថកិច្ចប្រចាំការ ដើម្បីគោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ពិនិត្យនិងសម្រេច។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមឯកឧត្តមជ្រាបនិងចាត់ចែងអនុវត្ត។

ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ទីស្តីការគណៈរដ្ឋមន្ត្រី

ង៉ែយ រឿន

**ចម្លងជូន៖**
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលខេត្តបន្ទាយមានជ័យ
- ឯកសារ កាលប្បវត្តិ

លេខ ០៦៩ ចល.កសក

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមលិខិតលេខ៤៩២ សជណ.កជ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី និងបញ្ជូនមកៈ

- ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

" ដើម្បីជូនជ្រាប "

- លោក លោកស្រី អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ឯកឧត្តម លោក លោកស្រី ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពាក់ព័ន្ធ

" ដើម្បីជ្រាប "

ថ្ងៃអង្គារ ៦ រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០២០

ត.ប រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អគ្គលេខាធិការ

ស្រី វុឌ្ឍី